**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកា ប្រចាំត្រីមាសទី៤ ឆ្នាំ២០២១
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២១ សរុបមានចំនួន ៣៥ ៤២៥,៤ លានរៀល ក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល៖** បានគ្រោងចំណូលសរុបចំនួន ៣៥ ៤២៤ លានរៀល ចំណូលនេះរួមមាន : (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន២០ ៩៩២ លានរៀល ស្មើនឹង៧៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ១១ ១៦២ លានរៀល ស្មើនឹង១០៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៣ ២៧០ លានរៀល ស្មើនឹង១១៤,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០។

(ខ) **មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត៖** បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង ១០០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ចំណូលនេះបានពីការជួលដីទំនេរនៃផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នៅក្នុងត្រីមាសទី៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូលបណ្តោះអាសន្ន សរុបមានចំនួន ១២ ២១២,៦លានរៀល ស្មើនឹង៣៤,៥ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៥៤,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល៖** អនុវត្តប្រមូលចំណូល សរុបមានចំនួន១២ ២១២,៦លានរៀល ស្មើនឹង៣៤,៥ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៥៤,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ចំណូលនេះរួមមាន (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន៧ ០៦៦,៩ លានរៀល ស្មើនឹង៣៣,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៧៧,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (២) ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន៤ ៥៣៥,៤ លានរៀល ស្មើនឹង ៤០,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៧១,២%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៣) ផលពីការផាក



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០

ពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន៤៤៧,៥ លានរៀល ស្មើនឹង១៣,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង ៣៥,២ % ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (៤) ផលពិសេសផ្សេងៗមានចំនួន ១៦២,៩លានរៀល គឺជាចំណូលពីការដោះដូរទីតាំង ដែលមិនបានគ្រោងនៅក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១។

**(ខ) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ៖**

នៅក្នុងត្រីមាសទី៤នេះមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ខេត្តកំពង់ស្ពឺមិនទាន់បានបង់ចំណូលពីថ្លៃឈ្នួលដីនៅឡើយដោយសារកិច្ចសន្យាជួលដីបានបញ្ចប់តាំងពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

ជារួមការអនុវត្តចំណូលរបស់រដ្ឋបាលកណ្តាលសម្រេចបានខ្ពស់។ ម្យ៉ាងទៀត ដោយពិនិត្យទៅតាមប្រភេទចំណូលនីមួយៗឃើញថាមានភាពកើនខ្ពស់ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ជាក់ស្តែងដូចជា៖

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបាន១៧៧,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះដោយសារចំណូលផលពីព្រៃឈើអនុវត្តបាន៣៥,៥%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៥៤៦,៧%ធៀបនឹងកម្មវិធីដែលបានដាក់ចេញនិងចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបាន៣២,១%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង១០៩,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវា អនុវត្តបានខ្ពស់គឺដោយសារចំណូលពីការលក់ឯកសារ លតាប័ត្រនិងលិខិតបោះពុម្ពផ្សេងៗអនុវត្តបាន១៣៥,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។ ចំណូលពីការអនុញ្ញាតរដ្ឋបាលទម្រង់ការរដ្ឋបាលនិងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ អនុវត្តបានចំនួន៣៥,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១០៤,១%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ចំពោះការជួលទ្រព្យសម្បត្តិរដ្ឋអនុវត្តបាន៣៤,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង២១០,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ ការសម្រេចបានលទ្ធផលនេះគឺដោយសារការជួលដីមានអគារអនុវត្តបាន ៧៦,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៧០,៨%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ រីឯចំណូលពីការជួលដីទំនេរអនុវត្តបានទាបគឺ១០,៥%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១។ ដោយឡែកចំណូលផលពីការគ្រប់គ្រងរដ្ឋបាលអនុវត្តបាន៤៣,៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៨៦,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញក្នុងនោះការត្រួតពិនិត្យអនាម័យសត្វអនុវត្តបាន៣៣%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៤២,៣%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការត្រួតពិនិត្យគុណភាពផលិតផលនិងការគោរពបទដ្ឋាន អនុវត្តបាន៥៥,៩%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង២៣៧,៩%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(៣) ចំណូលពីការផាកពិន័យ និងដាក់ទណ្ឌកម្មអនុវត្តបាន១៣,៧%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៣៥,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ លទ្ធផលនេះបានមកដោយសារការផាកពិន័យលើផលិតផលសាច់សត្វនិងការដឹកជញ្ជូនសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ អនុវត្តបាន១៧៥ %ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១០០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការទិញ-លក់ជីនិងថ្នាំកសិកម្មខុសច្បាប់ អនុវត្តបាន១១,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៥០%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន៥៥,៤%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៩៨,៤%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបាន១០,១ %ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១៦,៦%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ប្រាក់ពិន័យតាមសាលក្រមតុលាការអនុវត្តបាន៥៦,៨%%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១០១,៥%ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

**III-ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅ

តាមកម្មវិធីចំណូលប្រចាំត្រីមាសទី១ឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន៩ ៧៣៤,២លានរៀល។ កិច្ចការបន្ទាប់មួយទៀតដែលក្រសួងត្រូវអនុវត្ត គឺ រៀបចំកិច្ចប្រជុំពិភាក្សាជាមួយអង្គភាពពាក់ព័ន្ធលើការដាក់ឱ្យអនុវត្តការបង់ចំណូលតាមប្រព័ន្ធe-payment ។

IV-**សេចក្តីសន្និដ្ឋាន**

សរុបសេចក្តីមកការអនុវត្តប្រមូលចំណូលបណ្តោះអាសន្នប្រចាំត្រីមាសទី៤ របស់រដ្ឋបាលកណ្តាលសម្រេចបានលទ្ធផលល្អប្រសើរគឺលើសផែនការធៀបនឹងកម្មវិធីដែលបានដាក់ចេញទាំងផ្នែកចំណូលពីសេវាសាធារណៈ និងការជួលដីធ្លី ។ ទោះបីយ៉ាងនេះក្តីការអនុវត្តចំណូលមួយចំនួននៅទាបធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១ ដូចជាចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល ចំណូលពីការលក់ផលិតផលកសិកម្មនិង ចំណូលពីសម្បទានដីសេដ្ឋកិច្ច។ម្យ៉ាងទៀត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺក៏មិនទាន់បានអនុវត្តប្រមូលចំណូលពីថ្លៃឈ្នួលដីទំនេរផងដែរ។

ដូច្នេះដើម្បីបន្តអនុវត្តប្រមូលចំណូលឲ្យបានកាន់តែល្អប្រសើរតាមផែនការឆ្នាំ២០២២ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបន្តការយកចិត្តទុកដាក់ក្នុងការប្រមូល និងបង់ចំណូលឲ្យបានទាន់ពេលវេលា គួបផ្សំនឹងការប្រតិបត្តិតាមនីតិវិធីថ្មីៗពាក់ព័ន្ធការបង់ចំណូលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ថ្ងៃពុធ ៩កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២

**អនុរដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណាយថវិកាប្រចាំត្រីមាសទី៤ ឆ្នាំ២០២១
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សេចក្តីផ្តើម**:

ឆ្នាំ២០២១ គឺជាឆ្នាំទី៦ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តថវិកាកម្មវិធីពេញលេញដោយឈរលើគោលបំណងគោលនយោបាយរួមមួយគឺ "ជំរុញកំណើនកសិកម្មប្រកបដោយការប្រកួតប្រជែង ផលិតផលមានគុណភាព សុវត្ថិភាព និងអាហារូបត្ថម្ភព្រមទាំងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានដី ព្រៃឈើ និងជលផលប្រកបដោយចីរភាព"។ ដើម្បីឈានទៅសម្រេចគោលបំណងនេះ ក្រសួងបានដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តជាកម្មវិធី អនុកម្មវិធីនិងចង្កោមសកម្មភាពទៅតាមផ្នែកជំនាញនៃអង្គភាពថវិកាទាំង៤៦អង្គភាព ក្នុងនោះថ្នាក់កណ្តាលមានចំនួន២១អង្គភាពថវិកានិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន២៥ រាជធានីខេត្ត។

## I-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១

យោងតាមព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានគ្រោងឥណទានចំណាយថវិកា ឆ្នាំ២០២១ សរុបមានចំនួន ២៧៧ ៥៥៣ លានរៀល ក្នុងនោះ ៖

(ក) **រដ្ឋបាលកណ្តាល**៖ បានគ្រោងឥណទានចំណាយថវិកាសរុបចំនួន ១៨០ ២៧៧ លានរៀល រួមមាន៖

- ឥណទានចំណាយថវិកាចរន្ត មានចំនួន ១៦៤ ២៧៧ លានរៀល
- ឥណទានចំណាយថវិកាមូលធន មានចំនួន ១៦ ០០០ លានរៀល

(ខ) **មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត** ៖បានគ្រោងឥណទានចំណាយថវិកាចរន្តសរុបចំនួន ៩៧ ២៧៦ លានរៀល

## II-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ នៅក្នុងត្រីមាសទី៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អនុវត្តចំណាយបណ្តោះអាសន្នតាមអាណត្តិបើកប្រាក់សរុបចំនួន ៦៨ ៩៨៤,២លានរៀល ស្មើនឹង ២៤,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៦២,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបានចំនួន៤៩ ៤៨៩,២លានរៀលស្មើនឹង២៧,៥%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៦១,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ រីឯមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តអនុវត្តបានចំនួន១៩ ៤៩៥,៥ លានរៀល ស្មើនឹង២០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៦៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

(ក) រដ្ឋបាលកណ្តាល៖



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០

ដោយពិនិត្យទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឃើញថា ការអនុវត្តចំណាយបណ្តោះអាសន្នតាមអាណត្តិបើកប្រាក់របស់រដ្ឋបាលកណ្តាល(២១អង្គភាពថវិកា) សម្រេចបានចំនួន៤៩ ៤៨៩,២លានរៀលក្នុងនោះ៖ (១) ចំណាយចរន្តអនុវត្តបាន៤៦ ៣៤៩,២លានរៀល ស្មើនឹង២៨,២%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៧៥,២% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ ក្នុងនោះ៖(ក)ការទិញ(ជំពូក៦០) អនុវត្តបានចំនួន៩ ៧១៨,៥ លានរៀល ស្មើនឹង៤០,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៨១,៥% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន១២ ៣៩២,៣លានរៀលស្មើនឹង២៧,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៤៦,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ)បន្ទុកបុគ្គលិក(ជំពូក៦៤ ) អនុវត្តបានចំនួន១៩ ៩២៩,៧ លានរៀល ស្មើនឹង២៧,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង១១៨,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) ឧបត្ថម្ភធន (ជំពូក៦៥) អនុវត្តបានចំនួន៤ ១៨១,៦លានរៀល ស្មើនឹង១៨,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៧២,៣% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។ (២) ចំណាយមូលធនអនុវត្តបាន៣ ១៤០ លានរៀល ស្មើនឹង១៩,៦% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១។

ម្យ៉ាងវិញទៀត ដោយពិនិត្យលើចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិការបស់អង្គភាពរដ្ឋបាលកណ្តាល ឃើញថាទឹកប្រាក់សរុបចំនួន៤៩ ៤៨៩,២លានរៀល នេះត្រូវបានអនុវត្តចំណាយសម្រាប់៖

(១) បង្កើនផលិតភាព និងពិពិធកម្មកសិកម្ម និងកសិធុរកិច្ច (កម្មវិធីទី១) ចំនួន ៨ ៥៩១ លានរៀល ស្មើនឹង១៩,៧ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

(២) ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ( កម្មវិធីទី២) ចំនួន៤ ៦០៣,៧ លានរៀល ស្មើនឹង ៣៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

(៣) គ្រប់គ្រងធនធានជលផលនិងអភិវឌ្ឍវារីវប្បកម្ម (កម្មវិធីទី៣) ចំនួន៦ ៣៣៦,៣ លានរៀល ស្មើនឹង៤៥,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

(៤) គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃ (កម្មវិធីទី៤) ចំនួន ៥ ២៧៦,៣លានរៀល ស្មើនឹង៥១,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

(៥) បង្កើនប្រសិទ្ធភាពសេវាគាំទ្រនិងអភិវឌ្ឍន៍ធនធានមនុស្ស(កម្មវិធីទី៥) ចំនួន២៤ ៦៨១,៨លានរៀលស្មើនឹង២៤,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ។

**( ខ ) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ៖**

ផ្អែកតាមការពិនិត្យការអនុវត្តចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ឃើញថាមន្ទីរកសិកម្ម រុក្ខាប្រមាញ់និង នេសាទទាំង២៥រាជធានី ខេត្ត បានអនុវត្តចំណាយថវិកាតាមអាណត្តិបើកប្រាក់សរុបមានចំនួន ១៩ ៤៩៥,៥ លានរៀលក្នុងនោះចំណាយលើ៖ (ក) ការទិញ (ជំពូក៦០) អនុវត្តបានចំនួន១ ០៨១,១ លានរៀល ស្មើនឹង៩,១ % ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៦៨,៧% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ខ)សេវាកម្ម (ជំពូក៦១) អនុវត្តបានចំនួន៥ ៣៥៣,៥ លានរៀលស្មើនឹង២៣,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៦៦,៦% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (គ) បន្ទុកបុគ្គលិក (ជំពូក៦៤ ) អនុវត្តបានចំនួន១៣ ០២៥,៨លានរៀល ស្មើនឹង២៣,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៨៦,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ឃ) អត្ថប្រយោជន៍សង្គម (ជំពូក៦២) អនុវត្តបានចំនួន៨១,១លានរៀល ស្មើនឹង១,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬស្មើនឹង៩,៩% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ (ង) ជំពូក៦៣ (ពន្ធនិងអាករ) អនុវត្តបានចំនួន១៧,១លានរៀល ស្មើនឹង២២,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ឬស្មើនឹង៤៦,១% ធៀបនឹងកម្មវិធីដែលបានដាក់ចេញ។

ម្យ៉ាងទៀតពិនិត្យទៅតាមចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិកា តួលេខអនុវត្តចំណាយថវិកាសរុប ចំនួន ១៩ ៤៩៥ ៥៩៧ ២៦៦ លានរៀល ត្រូវបានអនុវត្តដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តដូចខាងក្រោម៖

ឯកតា: រៀល

| មន្ទីររាជធានីខេត្ត | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ | ការអនុវត្តត្រីមាសទី៤ | %ធៀបច្បាប់ហិរញ្ញវត្ថុ២០២១ | %ធៀបកម្មវិធីត្រីមាសទី៤ |
|---|---|---|---|---|
| បន្ទាយមានជ័យ | 3 711 100 000 | 1 018190 970 | 27.4% | 58.4% |
| បាត់ដំបង | 6 489 100 000 | 1 195 168 288 | 18.4% | 92.3% |
| កំពង់ចាម | 3 949 300 000 | 887 663 389 | 22.2% | 96.3% |
| កំពង់ឆ្នាំង | 3 878 800 000 | 436 764 800 | 11.3% | 64.1% |
| កំពង់ស្ពឺ | 4 923 900 000 | 1 073 038 710 | 21.8% | 110.9% |
| កំពង់ធំ | 5 497 900 000 | 835 688 882 | 15.2% | 54.6% |
| កំពត | 3 999 000 000 | 902 872380 | 22.6% | 77.8% |
| កណ្តាល | 6 180 000 000 | 1 178 862 633 | 19.1% | 79.1% |
| កោះកុង | 2 498 100 000 | 362 816 212 | 14.5% | 82.6% |
| ក្រចេះ | 3 903 800 000 | 1 041 109 182 | 26.7% | 177.4% |
| មណ្ឌលគិរី | 2 898 400 000 | 624 891 450 | 21.6% | 66.4% |
| រាជធានីភ្នំពេញ | 4 333 100 000 | 861 913 690 | 19.9% | 103.4% |
| ព្រះវិហារ | 2 924 700 000 | 426 444 600 | 14.6% | 66.9% |
| ព្រៃវែង | 4 515 000 000 | 1 680 372 700 | 37.2% | 94.6% |
| ពោធិ៍សាត់ | 3 875 200 000 | 597 838 680 | 15.4% | 48.6% |
| រតនគិរី | 3 080 700 000 | 597 838 680 | 19.4% | 100.5% |
| សៀមរាប | 5 712 400 000 | 732 880 780 | 12.8% | 62.8% |
| ព្រះសីហនុ | 2 887 000 000 | 548 078 550 | 18.9% | 51.5% |
| ស្ទឹងត្រែង | 3 270 000 000 | 418 374 390 | 12.8% | 40.1% |
| ស្វាយរៀង | 2 894 700 000 | 877 377 400 | 30.3% | 76.9% |
| តាកែវ | 5 153 600 000 | 770 474 809 | 14.9% | 86.3% |
| ឧត្តរមានជ័យ | 3 007 100 000 | 539 504 400 | 17.9% | 96.8% |
| កែប | 1 717 500 000 | 389 421 900 | 22.7% | 88.9% |
| ប៉ៃលិន | 2 285 800 000 | 318 765 240 | 13.9% | 71.1% |
| ត្បូងឃ្មុំ | 3 689 800 000 | 1 189 204 551 | 32.2% | 66.5% |

### III-បញ្ហាប្រឈម

យោងតាមការអធិប្បាយខាងលើឃើញថា ការអនុវត្តចំណាយថវិកាបណ្តោះអាសន្នប្រចាំត្រីមាសទី៤ឆ្នាំ២០២១ សម្រេចបានទាបជាងឆ្នាំ២០២០ក្នុងរយៈពេលដូចគ្នា ដោយសារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានកែសម្រួលនីតិវិធីមួយចំនួន ដើម្បីឆ្លើយតបនឹងការផ្ទុះជំងឺឆ្លងធ្ងន់ធ្ងរកូវីដ-១៩ តាមរយៈការចេញនូវប្រកាសណែនាំស្តីពីនីតិវិធីថ្មី៦ពាក់ព័ន្ធការចំណាយរដ្ឋទេយ្យបុរេប្រទាន ការចំណាយប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស ការចំណាយរៀបចំវគ្គបណ្តុះបណ្តាលសិក្ខាសាលា សន្និសីទ និងកិច្ចប្រជុំផ្សេងៗ ។ ការងារនេះតម្រូវឲ្យអង្គភាពថវិកានីមួយៗ សិក្សាស្វែងយល់ឲ្យបានច្បាស់

លាស់និងត្រូវរៀបចំឯកសារពាក់ព័ន្ធមួយចំនួន ដើម្បីអាចអនុវត្តការចំណាយបានទាន់ពេលវេលា។

ទន្ទឹមនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួបបញ្ហាប្រឈមមួយចំនួនដែលធ្វើឲ្យដំណើរការចំណាយមានការយឺតយ៉ាវខ្លះៗ ទាំងចំណាយចរន្តនិងចំណាយមូលធនដែលបញ្ហាលំបាកទាំងនោះមានដូចជាៈ

-ការផ្តល់ធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភាពយឺតយ៉ាវដែលនាំឲ្យរាំងស្ទះដល់ការងារអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ( ចំណាយចរន្តនិងមូលធន)

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនទាន់ចេញបទដ្ឋានគតិយុត្តពាក់ព័ន្ធចំណាយតាមនីតិវិធីទូទាត់ត្រង់ ដែលផ្ទេរពីចំណាយរដ្ឋទេយ្យបុរេប្រទាន

-ឯកសារគាំទ្រសម្រាប់ជម្រះទូទាត់រដ្ឋទេយ្យបុរេប្រទានរបស់អង្គភាពថវិកាមួយចំនួនមិនទាន់បំពេញបានគ្រប់គ្រាន់និងទាន់ពេលវេលា។

## IV-**ទិសដៅអនុវត្តបន្ត**

អង្គភាពថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវខិតខំអនុវត្តចំណាយថវិកាក្នុងការធ្វើសកម្មភាពការងារដើម្បីសម្រេចបានសូចនាកររបស់ខ្លួនទៅតាមកម្មវិធីចំណាយប្រចាំត្រីមាសទី១ឆ្នាំ២០២២ ដែលមានទឹកប្រាក់សរុបចំនួន ៦០ ៥២៧ ២៤១ ០០០រៀល ក្នុងនោះរួមមាន ៖

ឯកតាៈ រៀល

| ចំណាត់ថ្នាក់សេដ្ឋកិច្ច | រដ្ឋបាលកណ្តាល | មន្ទីររាជធានី ខេត្ត |
|---|---|---|
| ជំពូក ៦០ (ការទិញ) | 3 300 000 000 | 2 876 811 000 |
| ជំពូក ៦១ (សេវាកម្ម) | 5 100 000 000 | 4 889 931 000 |
| ជំពូក ៦៤ (បន្ទុកបុគ្គលិក) | 23 513 600 000 | 13 658 416 000 |
| ជំពូក៦២(អត្ថប្រយោជន៍សង្គម) | | 1 476 583 000 |
| ជំពូក ៦៥ (ឧបត្ថម្ភធន) | 5 711 900 000 | |
| ជំពូក ៦៣ (ពន្ធនិងអាករ) | | |
| **សរុប** | **37 625 500 000** | **22 901 741 000** |

## V-**សេចក្តីសន្និដ្ឋាន**

ឆ្លងតាមការពិនិត្យវាយតម្លៃការអនុវត្តចំណាយថវិកាបណ្តោះអាសន្នប្រចាំត្រីមាសទី៤ របស់អង្គភាពនៃរដ្ឋបាលកណ្តាលនិងមន្ទីររាជធានីខេត្ត ជារួមសម្រេចបាន៦២,១% នៃកម្មវិធីដែលបានដាក់ចេញ លទ្ធផលនេះនៅទាបជាងឆ្នាំ២០២០ក្នុងរយៈពេលដូចគ្នា ក្នុងនោះរដ្ឋបាលកណ្តាលអនុវត្តបាន៦១,៧% នៃកម្មវិធីដែលបានដាក់ចេញ។ ជារួមលទ្ធផលនេះគឺដោយសារការទូទាត់ចំណាយតាមនីតិវិធីលទ្ធកម្មមិនទាន់ចប់រួចរាល់ ទន្ទឹមនេះការទូទាត់ចំណាយតាមនីតិវិធីទូទាត់ត្រង់ដែលមានទឹកប្រាក់យ៉ាងច្រើននោះ កំពុងដំណើរការទូទាត់នៅចុងឆ្នាំ។ ម្យ៉ាងទៀតភាពយឺតយ៉ាវនៃការទូទាត់បណ្តាលមកពីការផ្លាស់ប្តូរនីតិវិធីចំណាយដែលតម្រូវឲ្យមានការកែប្រែផែនការគណនេយ្យ គួបផ្សំនឹងភាពរអាក់រអួលនៃដំណើរការទូទាត់នៅផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ដោយឡែកការអនុវត្តចំណាយថវិការបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមសម្រេចបានបង្គួរក្នុងកម្រិត ៦៣% នៃកម្មវិធីដែលបានដាក់ចេញ។ ទោះបីជាយ៉ាងនេះក្តី មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់អនុវត្តចំណាយថវិកាបានទាបដែលត្រូវធ្វើការជំរុញនិងកែលម្អបន្ថែមទៀត។

សរុបសេចក្តីមក ការអនុវត្តចំណាយថវិកាបណ្តោះអាសន្ន តាមអាណត្តិបើកប្រាក់ប្រចាំត្រីមាសទី៤ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជារួមនៅតែទទួលបានលទ្ធផលល្អ ទោះបីជាមានការកែសម្រួលនីតិវិធីមួយចំនួននិងធ្វើឲ្យ

ការអនុវត្តចំណាយលើការទិញនិងចំណាយសេវាកម្មអនុវត្តបានទាបក្តី ។ ការអនុវត្តចំណាយប្រភេទនេះនឹងមានភាពល្អប្រសើរក្នុងឆ្នាំ២០២២នេះ ប្រសិនបើស្ថានភាពនៃការឆ្លងជំងឺកូវីដ-១៩ កាន់តែបានធូរស្រាលនិងឈានទៅបិទបញ្ចប់។

ថ្ងៃពុធ ៩ កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២

**អនុរដ្ឋលេខាធិការ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**